# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍**

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

**សំណុំរឿងរដ្ឋប្បវេណី**

លេខ: ០៣៣

ចុះថ្ងៃទី២៣.០១.២០១៣

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី០១.០៤.២០១៣

**សាលដីកា**

លេខ: ០៨ក្រIV(ច)

ចុះថ្ងៃទី០១.០៤.២០១៣

### សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### ក្រឡាបញ្ជី—

លោក [redacted]

-ដើមចោទឈ្មោះ[redacted] ផូ ភេទប្រុស អាយុ៦២ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ី បម្រើកងហោះហើរដឹកជញ្ជូនសម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន មានទីលំនៅបច្ចុប្បន្នភូមិថ្មី ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល ។

-ចុងចម្លើយឈ្មោះ[redacted] វណ្ណថង ភេទស្រី អាយុ៦២ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីមន្ត្រីចូលនិវត្តន៍ មានទីលំនៅផ្ទះលេខD1 ភូមិ០៧ ក្រុម២២ ផ្លូវលេខ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ[redacted] ណាំ (ស) ម្តាយឈ្មោះ[redacted] ឡាញ់ (ស) ប្តីឈ្មោះ[redacted] ផូ មានកូន ០២ នាក់ ។

មេធាវីតំណាងដោយអាណត្តិឈ្មោះ[redacted] បញ្ញា , [redacted] មុន្នីជាតិ , [redacted] គីណាល់ ។

### កម្មវត្ថុបណ្តឹង:

**ដើមចោទទាមទារ:**

-សុំលែងលះពីប្រពន្ធឈ្មោះ[redacted] វណ្ណថង

-សុំសិទ្ធិគ្រប់គ្រងផ្ទះលេខ D1 ភូមិ៧ ក្រុម២២ ផ្លូវលេខ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

<u>អង្គហេតុ និងចំណុចវិវាទ</u>

តាមពាក្យបណ្តឹងចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១២ របស់ដើមចោទឈ្មោះ[redacted] ផូ បានបញ្ជាក់ថា ខ្លួនមានប្រពន្ធ ហើយខ្លួនក៏ទៅទាក់ទងជាមួយឈ្មោះ[redacted] វណ្ណថង ដែលជា ស្រីកំណាន់ចិត្តរហូតមានកូន ២នាក់ ហើយមើលឃើញជីវភាពខាង[redacted] វណ្ណថង មានការខ្វះខាត ទើបរូបខ្លួនយកកូនស្រីទាំងពីរមកចិញ្ចឹមបីបាច់ជាមួយប្រពន្ធ បន្ទាប់មកប្រពន្ធ



Scanned with CamScanner

ជីវភាពខាង [redacted] វណ្ណថង មានការខ្វះខាត ទើបប្ដូរខ្លួនយកកូនស្រីទាំងពីរមកចិញ្ចឹមបីបាច់ជាមួយប្រពន្ធ បន្ទាប់មកប្រពន្ធខ្លួនបានស្លាប់ទៅ ចំណែកខ្លួនជាប់រវល់បម្រើការងារនៅអង្គភាពទាំងយប់ ទាំងថ្ងៃ ស្រាប់តែឈ្មោះ [redacted] វណ្ណថង ដែលជាម្ដាយរបស់កូនទាំងពីរនាក់ បានឡើងមករស់នៅលើផ្ទះរបស់ខ្លួន ដោយគ្មានការអនុញ្ញាតពីខ្លួនដែលជាម្ចាស់ផ្ទះនោះ ។ ហើយកន្លងមកខ្លួនបានប្ដឹងទៅអាជ្ញាធរ សង្កាត់បឹងត្របែកផងដែរ ហើយអាជ្ញាធរសង្កាត់បានកោះហៅ ឈ្មោះ [redacted] វណ្ណថង ឱ្យចូលមកដោះស្រាយតែឈ្មោះ [redacted] វណ្ណថង ពុំចូលខ្លួនមកដោះស្រាយតាមកាលកំណត់ឡើយ ។

## ការអះអាងរបស់គូភាគី

-ដើមចោទឈ្មោះ [redacted] ផូ (វត្តមាន)

-ចុងចម្លើយឈ្មោះ [redacted] វណ្ណថង (វត្តមាន)

-មេធាវីតំណាងដោយអាណត្តិ [redacted] បញ្ញា, [redacted] គីណាល់ (វត្តមាន)

ចុងចម្លើយឈ្មោះ [redacted] វណ្ណថង បានថ្លែងថា ខ្លួនសុំបដិសេធរឿងលែងលះ សុំសិទ្ធិរស់នៅលើផ្ទះតទៅទៀត ។ ផ្ទះនេះជារបស់ប្រពន្ធដើមគាត់ ខ្លួនសុំផ្ទះទុកឱ្យកូន ។ លុយទិញផ្ទះជាចំណែករបស់ប្រពន្ធគាត់ គាត់បានយកលុយខ្លួនមកធ្វើរបងខាងមុខអស់ជាង ១តម្លឹងមាស ។ ហើយខ្លួនបានធ្វើបុណ្យឱ្យប្រពន្ធគាត់អស់ ១តម្លឹងមាសថា ខ្លួនជួសជុលផ្ទះអស់ ៤-៥តម្លឹង ។

មេធាវី [redacted] បានថ្លែងថា គាត់រស់នៅជាមួយកូនក្ដីរបស់ខ្លួនតាំងពីឆ្នាំ ១៩៨៧ ហើយកូនក្ដីខ្លួនបានយកលុយទៅជួសជុលផ្ទះអស់ជាច្រើនតម្លឹង គឺ ចំណាយប្រាក់ប្រហែល ១០តម្លឹងថែមទៀត ។

ដើមចោទឈ្មោះ [redacted] ផូ បានថ្លែងថា ខ្លួនសុំលែងលះ និងសុំនៅរក្សាដដែល ។ ផ្ទះនោះខ្លួនទិញនៅឆ្នាំ១៩៨៧ ដែលប្រាក់នោះជារបស់ប្រពន្ធដើមខ្លួន និងខ្លួន ។ គាត់ជួសជុលតែខ្លួនមិនព្រម ខ្លួនសុំនៅរក្សាដដែល ។

## សំអាងហេតុ

១-ពាក្យបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] វណ្ណថង ចុះថ្ងៃទី១៣-១១-២០១២ ប្ដឹងឧទ្ធរណ៍ នឹងសាលក្រមរដ្ឋប្បវេណីលេខ៤៩ "ណ" ចុះថ្ងៃទី ០៥-១១-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមបញ្ញត្តិមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-នាពេលទាញហេតុផលផ្ទាល់មាត់នៅសាលាឧទ្ធរណ៍ដើមចោទឈ្មោះ [redacted] ផូ នៅតែប្ដឹងសុំលែងលះប្រពន្ធឈ្មោះ [redacted] វណ្ណថង ដដែលដោយមូលហេតុថា រស់នៅមិនចុះសម្រុងគ្នា ហើយប្រពន្ធខ្លួនមិនយកចិត្តទុកដាក់ជាមួយខ្លួនទៀត រីឯចុងចម្លើយឈ្មោះ [redacted] វណ្ណថង មិនឯកភាពលែងលះទេ ។ ចំណុចនេះមិនឯកភាពគ្នាទេ ក្រុមប្រឹក្សាយល់ថា គូភាគីរស់នៅមិនចុះសម្រុងគ្នា ហើយដើមចោទអស់មនោសញ្ចេតនាមិនចង់រួមរស់ជាមួយប្រពន្ធឈ្មោះ [redacted] វណ្ណថង ទៀតទេ ។ ហេតុនេះគប្បីសម្រេចឱ្យគូភាគីលែងលះគ្នា ។

៣១៣

៣-ចំពោះចំនុចវិវាទគឺ ផ្ទះលេខD1 ផ្លូវលេខ៩៧ ក្រុម២២ ភូមិ៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ភាគីដើមចោទឈ្មោះ [redacted] ផូ បានអះអាងថា ជាទ្រព្យអោយឡែក របស់ខ្លួនមានជាមួយប្រពន្ធមុនឈ្មោះ [redacted] អ៊ូន ដូចមានបញ្ជាក់ក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០១១១០៧-០០៤៨ ចុះថ្ងៃទី ១៩-០៥-២០១០ ។ រីឯចុងចម្លើយក៏ទទួលស្គាល់ថា ផ្ទះលេខD1 ផ្លូវលេខ៩៧ នេះពិតជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទជាមួយប្រពន្ធមុនមែន ប៉ុន្តែប្រពន្ធមុនរបស់ដើមចោទបានសន្យាទុកផ្ទះនេះចែកឱ្យកូនឈ្មោះ [redacted] សោភ័ណ្ឌរស្មី , [redacted] សោភ័ណ្ឌណារ៉ា ដែលជាកូនរបស់ខ្លួន ជាមួយដើមចោទ ព្រោះប្រពន្ធមុនគ្មានកូនជាមួយដើមចោទទេ ។ ហេតុនេះខ្លួនសុំទាមទារសិទ្ធិគ្រប់គ្រងផ្ទះលេខD1 ផ្លូវលេខ៩៧ ខាងលើនេះទុកឱ្យកូន ។ ចំពោះផ្ទះលេខD1 នេះក្រុមប្រឹក្សាយល់ឃើញថា ជាទ្រព្យដោយឡែករបស់ដើមចោទ ហេតុដូចនេះចុងចម្លើយគ្មានសិទ្ធិទាមទារសិទ្ធិគ្រប់គ្រង ឬបែងចែកទ្រព្យនេះទេ ។ ហេតុនេះគប្បីច្រានចោលការទាមទាររបស់ចុងចម្លើយ ។

៤-ចុងចម្លើយអះអាងថា ផ្ទះលេខD1 នេះខ្លួនបានចំណាយប្រាក់អស់មួយចំនួនប្រហែលជា០៤ទៅ០៥តម្លឹងមាស ដើម្បីជួសជុលផ្ទះនេះ ។ ចំណុចនេះដើមចោទទទួលស្គាល់ថា ចុងចម្លើយពិតជាបានចំណាយប្រាក់មួយចំនួនជួសជុលមែនតែតិចតួចទេ ប្រហែល០១តម្លឹងមាស ហើយខ្លួនក៏បានហាមដែរ តែចុងចម្លើយមិនស្តាប់ ។ ចំណុចនេះក្រុមប្រឹក្សាយល់ថា ចុងចម្លើយបានចូលរួមចំណែកមួយចំនួនតាមរយៈការជួសជុលកែលំអរ ធ្វើឱ្យបង្កើនតំលៃនៃផ្ទះ D1 នេះហេតុនេះចុងចម្លើយគប្បីទទួលបាននូវប្រាក់ចំណាយមួយចំនួនដែលខ្លួនបានចំណាយជួសជុល ។ ការអះអាងរបស់ចុងចម្លើយថា បានចំណាយអស់០៤ ទៅ០៥តម្លឹងមាសនោះគ្មានមូលដ្ឋានច្បាស់លាស់គួរឱ្យជឿទេ ប៉ុន្តែដើមចោទទទួលស្គាល់ថា បានចំណាយតិចតួច មិនដល់០៤ទៅ០៥តម្លឹងមាសទេ គឺអស់ប្រហែល០១តម្លឹងមាស គ្រាន់តែធ្វើរបងប៉ុណ្ណោះ ។ ហេតុដូចនេះក្រុមប្រឹក្សាគួរសម្រេចយកតាមភាពសមហេតុផល ។

៥-សំអាងហេតុនៃសាលក្រមរដ្ឋប្បវេណីលេខ ៤៩ "ណ" ចុះថ្ងៃទី០៥-១១-២០១២ របស់សាលាដំបូងមានលក្ខណៈត្រឹមត្រូវ ហើយលើកលែងតែសំអាងហេតុក្នុងចំណុចទី៧ ។ សាលាឧទ្ធរណ៍ឯកភាពនឹងសំអាងហេតុនេះ លើកលែងតែសំអាងហេតុក្នុងចំណុចទី៧ ។

៦-សាលក្រមរដ្ឋប្បវេណីលេខ៤៩ "ណ" ចុះថ្ងៃទី០៥-១១-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចមកត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១-ច្រានចោលបណ្តឹងឧទ្ធរណ៍របស់ចុងចម្លើយឈ្មោះ [redacted] វណ្ណថង ចុះថ្ងៃទី១៣-១១-២០១២ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៤៩ "ណ" ចុះថ្ងៃទី០៥-១១-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣-បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] ផូ សងប្រាក់ថ្លៃជួសជុលផ្ទះលេខ D1 ផ្លូវ៩៧ ភូមិ៧ ក្រុម២២ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ចំនួន០៣តម្លឹងមាស ទៅឈ្មោះ [redacted] វណ្ណថង ។



Scanned with CamScanner

៤-ប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ជាបន្ទុករបស់ចុងចម្លើយឈ្មោះ [redacted]វណ្ណផង ។

សាលដីកានេះទាញហេតុផលផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី-០១-០៤-២០១៣ ។

បើកផ្លូវប្តឹងសាទុក្ខក្នុងរយៈពេល ០១ខែ គិតពីថ្ងៃបានទទួលសាលដីកានេះ ។

ក្រឡាបញ្ជី ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សា

ហត្ថលេ[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

ភ្នំពេញ,ថ្ងៃទី..០២...ខែ..សីហា..ឆ្នាំ២០១៣

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ក្រឡាបញ្ជី**

[redacted]

[redacted]

៣១៥